ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ០៧២/២៥ ក.ប/ស.ជ.ណ.ម.អ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
# សម្រាប់ពលករជំនាញដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងប្រព័ន្ធពលករជំនាញឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុននឹងរៀបចំការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនសម្រាប់ពលករជំនាញ តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

| ល.រ | ប្រភេទតេស្ត | កាលបរិច្ឆេទធ្វើតេស្ត | មណ្ឌល | តម្លៃចុះឈ្មោះ |
|---|---|---|---|---|
| ១ | ផ្នែកសំណង់ | ថ្ងៃទី៥, ៦, ១២, ១៥,១៧ និង២៤ ខែសីហា ឆ្នាំ២០២៥<br>ថ្ងៃទី១, ២, ៧, ៨, ១២ និង១៤ ខែកញ្ញា ឆ្នាំ២០២៥ | វិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ (EDI) | ៧ដុល្លារ |
| ២ | ផ្នែកកសិកម្ម | ថ្ងៃទី៥, ៦, ១២, ១៥,១៧ និង២៤ ខែសីហា ឆ្នាំ២០២៥<br>ថ្ងៃទី១, ២, ៧, ៨, ១២ និង១៤ ខែកញ្ញា ឆ្នាំ២០២៥ | | ៣៣ដុល្លារ |

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន គឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- ព័ត៌មានអំពីមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖
  - ❖ វិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ (EDI)
    - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - លេខទូរសព្ទ៖ +855 12 937 168 / +855 16 862 868 / +855 15 729 123 / +855 12 269 768
- សេវានៃការចុះឈ្មោះធ្វើតេស្ត គឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- **ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្ត៖**
  - ❖ អត្តសញ្ញាណបណ្ណ លិខិតឆ្លងដែន ឬបណ្ណបើកបរ
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលទៅគេហទំព័រ https://ac.prometric-jp.com/testlist/ssw/index.html

**បញ្ជាក់៖** កាលបរិច្ឆេទនៃការធ្វើតេស្តខាងលើនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញទាំង ២ផ្នែកខាងលើ ជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១២កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**ចម្លងជូន៖**
- -សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)
- -ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
  - "ដើម្បីផ្សព្វផ្សាយ"
- -ឯកសារ កាលប្បវត្តិ